# ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៥

## ស្តីពី

## សញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា កាលពី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំដំបូងនីតិកាលទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១៣៧ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរងនៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីសំរេចលេខ ០៤១/១១០៥/ពស/សរ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា ។

## គ្រាសប់បន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :**

ត្រូវបានបង្កើតសញ្ញាសក្តិ និងឯកសណ្ឋាន សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**មាត្រា ២ :**

សញ្ញាសក្តិរួមមាន សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និងសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ឯកសណ្ឋានរួមមាន ឯកសណ្ឋានផ្លូវការ និង ឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ ពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី ២

## អំពីសញ្ញាសក្តិ

**មាត្រា ៣ :**

សញ្ញាសក្តិនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចតទៅ ÷

**១ . ក្របខ័ណ្ឌមន្ត្រីអភិបាល**

**ក . សក្តិចុងកអាវ**

សក្តិចុងកអាវមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយនៅផ្នែកខាងដើម និងខាងក្រោមតួសក្តិមានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។ នៅផ្នែកកណ្តាលរហូតខាងចុងនៃតួសក្តិមានក្បាច់ភ្ញីវល្លិពណ៌មាសរចនាជាសន្លឹកផ្លែ និងផ្កា ដែលតំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ហើយមានក្បាច់ត្របកឈូកពណ៌មាស នៅពីខាងក្រោមក្បាច់ភ្ញីវល្លិ និងសញ្ញាសម្គាល់ ។ នៅជាយនៃតួសក្តិចុងកអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាសនៅជ្រុងខាងដើម ចំនួន០៣ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិ ឧត្តមអភិបាល ចំនួន០២ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិ អភិបាល ។ នៅពីផ្នែកខាងលើ និងផ្នែកខាងចុងនៃសញ្ញាសក្តិចុងកអាវមានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

- មានរាងជាប្រលេឡូក្រាម
- បណ្តោយ ប្រវែង ០៨.០០ សង់ទីម៉ែត្រ
- ទទឹង ប្រវែង ០៣.៥០ សង់ទីម៉ែត្រ

**ខ . សក្តិស្មា**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិពណ៌មាសចំកណ្តាល ដែលមានជាសន្ទឹក ផ្លែ និងផ្កា តំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ។ នៅពីខាងលើក្បាច់ភ្ញីវល្លិមានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ហើយនៅពីខាងលើសញ្ញាសម្គាល់នេះ មានឡេវរូបព្រះសង្ហារពណ៌មាសមួយដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់ទីម៉ែត្រ ។ ឡេវ សញ្ញាសម្គាល់ និងក្បាច់ភ្ញីវល្លិហ៊ុំព័ទ្ធជុំវិញដោយក្បាច់ត្របកឈូកពណ៌មាស ។ នៅ ជាយនៃគូសក្តិស្មាមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ចំនួន ០៣ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន ០២ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិអភិបាល ។

**ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

- បាតក្រោម ប្រវែង ០៦.០០ សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ០៤.៥០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣.០០ សង់ទីម៉ែត្រ ។

**គ . សក្តិចុងដៃអាវ**

សក្តិចុងដៃអាវមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិពណ៌មាស ដែលមានជាសន្ទឹក ផ្លែ និង ផ្កា តំណាងនូវដំណាំរួមផ្សំនៅកម្ពុជា មានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅចំកណ្តាលនៃក្បាច់ភ្ញីវល្លិ ហើយមានក្បាច់ត្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីវល្លិនៅជាយផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង។ នៅជាយនៃគូសក្តិចុងដៃអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ហ៊ុំព័ទ្ធជាបីជ្រុង គឺនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង ចំនួន០៣ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និងចំនួន ០១ ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់នៃសញ្ញាសក្តិចុងដៃអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងដៃអាវត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយ ប្រវែង ៣២.០០ សង់ទីម៉ែត្រ
- ទទឹង ប្រវែង ០៨.០០ សង់ទីម៉ែត្រ

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷**

- ឋានន្តរសក្តិឧត្តមអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១
- ឋានន្តរសក្តិវរអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ២
- ឋានន្តរសក្តិអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យនេះ ។

**ឃ . សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់រចនាលើសក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវ និង សម្រាប់ជាសក្តិកន្ទាស់ក្ខាស់លើអាវបុរស នារី ឬ លើក្រមាពាក់នារី សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល មាន រាងមូលទ្រវែង មានកម្ពស់ ០៦.០០ សង់ទីម៉ែត្រ ទទឹង ០៤.៥០ សង់ទីម៉ែត្រ ។

នៅផ្នែកខាងលើនៃសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានរចនាដោយជើងពានពីរជាន់ទ្រចតុកោណ កែងមួយ ពណ៌មាស ដែលមានចារឹកអក្សរព្រឹទ្ធសភា និងសៀវភៅរដ្ឋធម្មនុញ្ញមានរូបអង្គរពីខាងក្រោយ មានកាំរស្មី ចំនួន ២៤ មានភ្ញីស្លឹកឈើព័ទ្ធឡើងលើជាស្នែងក្របី ស្ថិតនៅខាងក្រោមជើងពាន ។ នៅផ្នែកកណ្តាល មាននាគ មួយគូ ពណ៌មាស ពាំកួរស្រូវ ចំនួន ០៥ គ្រាប់ក្នុងម្ខាង១ ។ នៅចំពាក់កណ្តាលនៃគូនាគមួយគូ មានរចនាលំអដោយ ក្បាច់ផ្កាចន្ទន៍ពណ៌មាស ។ នៅពីខាងក្រោយសញ្ញាសម្គាល់ មានផ្ទៃពណ៌ខៀវចាស់ ។ នៅពីក្រោមរូបនាគមួយគូ មាន រចនាជាបន្ទះសម្រាប់សរសេរអក្សរពណ៌ក្រហម និងនៅតាមជរជាយមានពណ៌ខៀវ ព័ទ្ធឡើងលើជាស្នែងក្របីភ្ជាប់ទៅ នឹងកួរស្រូវ ដែលក្នុងនោះមានចារឹកអក្សរខ្មែរថា **"អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា"** ជាពណ៌មាស ។

**២ . ក្របខ័ណ្ឌមន្ត្រីឧបការី**

សញ្ញាសក្តិ (សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និងសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា) សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានសណ្ឋាន រូបភាព និងមានការបែងចែកទៅតាមឋានន្តរសក្តិ ដូចសញ្ញា សក្តិមន្ត្រីក្របខ័ណ្ឌអភិបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាសក្តិ សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានពណ៌ប្រាក់។ ដោយ ឡែកសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលរចនាលើសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវ មាន ពណ៌មាស ។

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷**

- ឋានន្តរសក្តិនាយឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤
- ឋានន្តរសក្តិឧបការីដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥
- ឋានន្តរសក្តិឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦នៃព្រះរាជក្រឹត្យនេះ ។

**រូបគំនូរសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌ ឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធ ទី៧ នៃព្រះរាជក្រឹត្យនេះ ។**

**៣. សញ្ញាសក្តិសម្រាប់មន្ត្រីរាជការជានារី**

សក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវ សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ជានារី គឺដូចគ្នាគ្រប់ចំណុច និងគ្រប់ឋានន្តរសក្តិទាំងអស់របស់បុរស ប៉ុន្តែខុសគ្នាតែពីទំហំប៉ុណ្ណោះគឺ ÷

- សក្តិចុងកអាវ : អាចមានទទឹងពី ០៣ ទៅ ០៣.៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌនារី
- សក្តិស្មា : អាចមានទំហំ ៨០% ឬ ៨៥% ឬ ៩០% នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងដៃអាវ : អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំសក្តិចុងដៃអាវរបស់បុរស អាស្រ័យ លើមាឌរបស់នារី ។

## ជំពូកទី ៣

## អំពីឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៤ :**

ឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានកំណត់ដូចខាងក្រោម ÷

**១ . ឯកសណ្ឋានផ្លូវការ**

**ក . ចំពោះបុរស**

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ ដៃអាវវែង ហើយនៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ មានហោប៉ៅចោះបង្កប់ចំនួន ៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ( ពណ៌មាសសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ពណ៌ប្រាក់ សម្រាប់មន្ត្រីរាជការ ក្របខ័ណ្ឌឧបការី ) ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ បិទឡេវរូបព្រះសង្ហារ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌចំនួន ០៧ ដែលឡេវនីមួយៗ មានអង្កត់ផ្ចិតប្រវែង ០២.៥០ សង់ទីម៉ែត្រ ។

- ខោជើងវែងពណ៌ស គចង្កេះភ្ជិបកក្រោយខាងឆ្វេង ០២ ខាងស្តាំ ០២ ហោប៉ៅចំហៀងនៅសងខាង ហោប៉ៅចោះក្រោយ ០១ នៅខាងស្តាំ ។

- ស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ។

**ខ . ចំពោះនារី**

- អាវជីបរាង ពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ កត្រង់ គ្មានផែកខ្នង បិទឡេវមុខមានដាក់ឡេវរូបព្រះសង្ហារពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ចំនួន ០៥ មានអង្កត់ផ្ចិតប្រវែង ០២.៥០សង់ទីម៉ែត្រ។ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះសក្តិលើស្មាសម្រាប់ដាក់សក្តិមួយគូ មានហោប៉ៅចោះ ចំនួន ០៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដោយមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាលចោះរន្ធឡេវសំរាប់បិទ។ ដៃអាវវែង ត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

- សំពត់សំឡុយអំពីជាម្ចងពណ៌ខៀវ មានសម្រុងលើភ្នែកគោលនៃស្នងជើងប្រវែងពី ១០ ទៅ ១៥ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌ និង កម្ពស់។

- ស្បែកជើងអេស្កាប៉ាង ឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

**រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។**

**២ . ឯកសណ្ឋានប្រពៃណីជាតិ**

**ក . ចំពោះបុរស**

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ ដៃអាវវែង ហើយនៅចុងដៃអាវមានសក្តិចុងដៃអាវ ។ មានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាល ចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ បិទឡេវរូបព្រះសង្ហារពណ៌មាសចំនួន ០៧ ដែលឡេវ នីមួយៗមានអង្កត់ផ្ចិតប្រវែង ០២,៥០ សង់ទីម៉ែត្រ ។

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

**ខ . ចំពោះនារី**

- អាវជីបរាង ពណ៌ "ស" ដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិតប្រវែង ០១,៥០ សង់ទីម៉ែត្រ និងត្រង់ស្មាឃ្លាតពីគល់កប្រមាណ ០២,៥០ សង់ទីម៉ែត្រ ទៅ ០៣,០០ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី ។ អាវនេះ គ្មានសក្តិស្មា និងសក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមក្របខ័ណ្ឌ និង ឋានន្តរសក្តិ ។

- ពានាក្រមាពណ៌តាមសំពត់ ។ សាច់ក្រមា ដែលធ្វើអំពីសូត្រ មានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬ ពានាក្រមាពណ៌ស៊ីនួន ឬ តាមពិធីការកំណត់ ហើយនៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង ត្រូវក្លាស់ "**សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**" សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ។

- សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ

- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

- កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ( មិនឱ្យស្ពាយទេ ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

**រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។**

**មាត្រា ៥ :**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចខាងក្រោម ÷

- ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ឬ តាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន ។

- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និង សាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬ ក្នុងវត្តអារាម ឬ ទីកន្លែងផ្សេងៗ ត្រូវបានកំណត់ឱ្យប្រើសំរាប់តែមន្ត្រីរាជការក្របខ័ណ្ឌអភិបាល ដែលមានឋានន្តរសក្តិឧត្តមអភិបាល ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ក៏ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និង អន្តរជាតិ ឬ ក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី ៤
## របបកំណត់សញ្ញាសក្តិ និងឯកសណ្ឋាន

**មាត្រា ៦:**

សញ្ញាសក្តិ ឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ និងសម្ភារះផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានផ្តល់ជូនដល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី មួយសម្រាប់ក្នុងម្នាក់ៗ សម្រាប់ប្រើប្រាស់រយៈពេល ០៦ ឆ្នាំ ។

ការចំណាយលើសញ្ញាសក្តិ ឯកសណ្ឋានគ្រប់ប្រភេទ និងសម្ភារះផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះជាបន្ទុកថវិកាជាតិ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៧:**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨:**

ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គលេខាធិការព្រឹទ្ធសភា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

*ពស/រកត.០៧០១.០០៥*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧*

លេខ : ៣២ ច.ល
ចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
ឌិនរេន

# សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧត្តមអភិបាល (ពណ៌មាស)

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ថវអភិបាល (ពណ៌មាស)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ អភិបាល (ពណ៌មាស)



សក្តិស្មា



សក្តិចុងកអាវ



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ នាយឧបការី (ពណ៌ប្រាក់)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

# សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧបការីដើមខ្សែ (ពណ៌ប្រាក់)

ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



សក្តិស្មា



សក្តិចុងករអាវ



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៦ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧបការី (ពណ៌ប្រាក់)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

# សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យ លេខ ន.ស/រ.ក.ត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា




សម្រាប់ក្របខ័ណ្ឌអភិបាល (ពណ៌មាស)




សម្រាប់ក្របខ័ណ្ឌឧបការី (ពណ៌ប្រាក់)

# ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធទី៨ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



# ឯកសណ្ឋានប្រពៃណីជាតិ

ឧបសម្ព័ន្ធទី៩ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

